# សុន្ទរកថា

## របស់ឯកឧត្តម ស៊ុន ចាន់ថុលទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ថ្លែងក្នុងពិធីសំណេះសំណាលជាមួយកម្មករ កម្មការិនី បុគ្គលិកកំពង់ផែស្វយ័តក្រុងព្រះសីហនុ នាឱកាសទិវាពលកម្មអន្តរជាតិ លើកទី ១៣១

## ថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០១៧

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- សូមគោរពឯកឧត្តម **ម៉ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា!
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ បងប្អូនមន្ត្រីរាជការ កម្មករនិយោជិត នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) ទាំងអស់ ជាទីរាប់អាន!!!

ក្នុងបរិយាកាសដ៏សែនរីករាយក្រៃលែងនេះ ខ្ញុំព្រះករុណា-ខ្ញុំបាទ ក្នុងនាមថ្នាក់ដឹកនាំមន្ត្រីរាជការក្រសួងសាធារណការ និងដឹកជញ្ជូន ជាពិសេសក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំនិយោជិត និងកម្មករ នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានកិត្តិយសដ៏ឧត្តុង្គឧត្តម ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ម៉ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ** និងជា **រដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែលអញ្ជើញជាអធិបតីក្នុងឱកាសអបអរសាទរទិវាពលកម្មអន្តរជាតិលើកទី១៣១ នាថ្ងៃទី០១ ឧសភា ២០១៧។

ជំនួសមុខឲ្យអង្គពិធីទាំងមូល ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមសំដែងនូវការគោរពស្វាគមន៍យ៉ាងកក់ក្ដៅ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ វត្តមានដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** និងជារដ្ឋមន្ត្រីស្ដីទី ទទួលបន្ទុកទីស្ដីការគណៈ រដ្ឋមន្ត្រីតំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល

លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ដែលបានអញ្ជើញ ចូលរួមក្នុងពិធី នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា នាថ្ងៃនេះ ដែលញ៉ាំងឱ្យពិធីនេះ កាន់តែអធិកអធម និងមានអត្ថន័យ ថែមទៀត។

យើងខ្ញុំទាំងអស់គ្នា ដែលមានវត្តមាននៅក្នុងពិធីនេះ ក៏ដូចជាប្រជាជនកម្ពុជា ទូទាំងប្រទេស សូមចូលរួមសំដែងនូវការគោរពដឹងគុណជាទីបំផុត និងអបអរសាទរ ដ៏ជ្រាលជ្រៅ ចំពោះសមិទ្ធផលជាតិ ដ៏ត្រចះត្រចង់ ពាសពេញផ្ទៃប្រទេស ដែលប្រសូត្រចេញពីស្នាដៃនយោបាយដឹកនាំ ប្រកបដោយ ប្រាជ្ញាញាណឈ្លាសវៃរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**។

**ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីសក្ការៈ**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ ទាំងអស់ជាទីរាប់អាន!**

អនុញ្ញាតឱ្យ ខ្ញុំព្រះករុណា-ខ្ញុំបាទ រំលឹកត្រឡប់ទៅក្រោយបន្តិច អំពីដំណាក់កាលនៃការអភិវឌ្ឍកំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រោយពីប្រទេសជាតិ ទទួលបានសុខសន្តិភាពពេញលេញ ក្រោមការដឹកនាំដ៏ឈ្លាសវៃ របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានធ្វើឲ្យកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានលទ្ធភាពអភិវឌ្ឍ និងពង្រីកសមត្ថភាព របស់ខ្លួនជាបន្តបន្ទាប់ ដូចខាងក្រោម៖

- ឆ្នាំ ២០០២ ដល់ ឆ្នាំ ២០០៥ បានសាងសង់ផែកុងតេន័រ ប្រវែង ២៤០ម៉ែត្រ ជម្រៅទឹក ១១.៥ ម៉ែត្រ ចំណាយថវិកាអស់ចំនួន ៣៣.៧លានដុល្លារអាមេរិក។
- ឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៩ បានសាងសង់ផែកុងតេន័របន្ថែមប្រវែង ១៦០ម៉ែត្រ (បង្គ្រប់ ៤០០ម៉ែត្រ) ជម្រៅទឹក ១១.៥ ម៉ែត្រ និងបំពាក់មធ្យោបាយលើក-ដាក់កុងតេន័រ ចំណាយថវិកាអស់ចំនួន ៣៩.៨ លានដុល្លារអាមេរិក។
- ឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១២ បានសាងសង់តំបន់សេដ្ឋកិច្ចពិសេស ចំណាយថវិកាអស់ ចំនួន ៣៥.៩លានដុល្លារអាមេរិក។
- ឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ កំពុងសាងសង់ផែពហុបំណងប្រវែង ៣៣០ម៉ែត្រ ជម្រៅទឹក ១៣.៥ម៉ែត្រ និងចំណតមូលដ្ឋានផ្គត់ផ្គង់ភស្តុភារ សម្រាប់ការរុករកប្រេង ដែល មានបណ្តោយ ២០០ម៉ែត្រ ជម្រៅទឹក ៧.៥ម៉ែត្រ ដោយគ្រោងចំណាយថវិកាចំនួន ៧៤.២លានដុល្លារអាមេរិក។

• ចុងឆ្នាំ២០១៦ និងខែមករាឆ្នាំ២០១៧ បានបំពាក់មធ្យោបាយលើកដាក់កុងតេន័រទំនើប ចំនួន០២ សម្រាប់ប្រភេទQC (០២គ្រឿង) និងRTG (០៩គ្រឿង) សម្រាប់ការបង្កើនសមត្ថភាព និងគុណភាពសេវាកម្ម លើកដាក់កុងតេន័រ ដោយប្រើប្រាស់ថវិកាកំពង់ផែ ចំនួន២២លានដុល្លារអាមេរិក។

សរុបមកដល់បច្ចុប្បន្ននេះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ទទួលបានប្រាក់កម្ចីពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈភ្នាក់ងារ JICA របស់ជប៉ុន ប្រមាណ ១៧៨.៦លានដុល្លារអាមេរិក និងវិនិយោគថវិកាកំពង់ផែផ្ទាល់ ចំនួន២២លានដុល្លារអាមេរិក។

ផ្អែកលើអត្រាកំណើនសេដ្ឋកិច្ច របស់ប្រទេសកម្ពុជា ប្រកបដោយស្ថេរភាព និងរឹងមាំ ក្នុងរង្វង់ជាមធ្យម ៧% ប្រចាំឆ្នាំ បានធ្វើឲ្យបរិមាណកុងតេន័រឆ្លងកាត់កំពង់ផែកើនឡើង ជារៀងរាល់ឆ្នាំ ជាក់ស្តែង ឆ្នាំ២០១៤ មានកំណើន ១៦% ឆ្នាំ២០១៥ មានកំណើនជាង ១៧% និង ឆ្នាំ២០១៦ មានកំណើនជាង ៣%។ រួមជាមួយគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ តាមនិទស្សន៍បរិមាណកុងតេន័រឆ្លងកាត់កំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅឆ្នាំ២០២៣ខាងមុខ នឹងកើនលើស ៧០០,000TEUs (TEUs = Twenty Equivalent Units) ដែលលើសពីសមត្ថភាពកំពង់ផែនាពេលបច្ចុប្បន្ន។ ដូច្នេះ ដើម្បីឆ្លើយតបនឹងកំណើននេះ នៅឆ្នាំ២០២២ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ត្រៀមសាងសង់ចំណតផែកុងតេន័រប្រវែង ៣៥០ម៉ែត្រ ជម្រៅទឹក ១៤.៥ម៉ែត្រ និងបំពាក់ដោយមធ្យោបាយគ្រឿងចក្រទំនើបៗ ដែលគ្រោងចំណាយថវិកាប្រមាណ ២០០ លានដុល្លារអាមេរិក ។

ឆ្នាំ២០០៩ រាជរដ្ឋាភិបាល មានគោលការណ៍ឲ្យ កំពង់ផែស្វយ័តក្រុងព្រះសីហនុបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង (IPO) ។ គោលការណ៍នេះ តម្រូវឲ្យមានការសិក្សា ត្រួតពិនិត្យលើរបាយការណ៍គណនេយ្យ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ តាមលក្ខខណ្ឌ និងលក្ខណៈសម្បត្តិដែលតម្រូវពីអង្គភាពជំនាញ ។ ដោយកិច្ចខិតខំប្រឹងយ៉ាងខ្លាំងពីក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំ ក.ស.ស សហការជាមួយក្រុមហ៊ុនធានាទិញមូលបត្រ (SBI Royal) បានរៀបចំកម្មវិធីរ៉ូដស្ង និងប៊ុកបៀលឌីង (Roadshow & Book Building) ជាសាធារណៈ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ហើយ ក.ស.ស នឹងចុះបញ្ជីលក់មូលបត្រជាផ្លូវការ នូវក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ខាងមុខនេះ។

**ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីសក្ការៈ**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ ទាំងអស់ជាទីរាប់អាន !**

សមិទ្ធផលដែលសម្រេចដូចបានរៀបរាប់ខាងលើ គឺ ជាការឆ្លុះបញ្ចាំងឱ្យឃើញនូវការអភិវឌ្ឍ និងប្រែក្លាយកំពង់ផែស្វយ័តក្រុងព្រះសីហនុ របស់កម្ពុជា ជាកំពង់ផែមានលក្ខណៈអន្តរជាតិ ហើយបាននឹងកំពុងដើរតួនាទីយ៉ាងសកម្ម ជាច្រកទ្វារសេដ្ឋកិច្ចអន្តរជាតិ ជួយសម្រួលដល់ការនាំចូល និងនាំចេញទំនិញគ្រប់ប្រភេទ រួមចំណែកជំរុញកំណើនសេដ្ឋកិច្ចឲ្យកាន់តែរីកចំរើន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ បានកាន់តែឆាប់រហ័ស។

ឆ្លៀតក្នុងឱកាសនេះ អនុញ្ញាតឱ្យខ្ញុំព្រះករុណា-ខ្ញុំបាទ សូមគោរពថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅជាទីបំផុត ចំពោះការយកចិត្តទុកដាក់របស់ **សម្តេចតេជោ** ដែលជានិច្ចកាលតែងបានផ្តល់នូវអនុសាសន៍ណែនាំ សម្រាប់ជាត្រីវិស័យ ដល់វិស័យសាធារណការ និងដឹកជញ្ជូន ព្រមទាំង កិច្ចការកំពង់ផែ ជាហេតុធ្វើឱ្យវិស័យនេះ កាន់តែពង្រីកបាននូវសមត្ថភាព និងប្រសិទ្ធភាព ក្នុងការបម្រើសេវា ជូនដល់អតិថិជន និងសូមថ្លែងអំណរគុណផងដែរ ដល់អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់នូវកិច្ចសហការ សម្របសម្រួលដល់កិច្ចការពាណិជ្ជកម្ម សេវាកម្ម និងបានរួមចំណែកធ្វើឱ្យសេវានៅ ក.ស.ស កាន់តែល្អប្រសើរ និងមានទំនុកចិត្ត ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមប្រគេនពរ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមគោរពជូនពរ **ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស ជាតិ-អន្តរជាតិ កម្មករ និយោជិត សូមប្រកប តែពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ក្នុងខណៈនេះដែរ ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមអនុញ្ញាតដ៏ខ្ពង់ខ្ពស់ គោរពអញ្ជើញ **ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍សំណេះសំណាលក្នុងអង្គពិធី។ **សូមគោរពអញ្ជើញ**។

***សូមអរព្រះគុណ និង សូមអរគុណ !***